# សេចក្តីប្រកាសទទួលពាក្យស្នើសុំ៖
# «មូលនិធិដំឡើងស្នាដៃថ្មី ឆ្នាំ២០២៥»
## ស្នាដៃសិល្បទស្សនីយភាព ក្រោមមូលបទ «**វិវត្ត**»

| ព័ត៌មានសំខាន់ៗ | |
|---|---|
| **ឱកាស** | មូលនិធិ **«មូលនិធិដំឡើងស្នាដៃថ្មី ឆ្នាំ២០២៥»** |
| **បង្កើតឡើងដើម្បី** | គាំទ្រដល់សិល្បករជាឯកត្តជនឬសិល្បករជាក្រុម ក្នុងទម្រង់សិល្បទស្សនីយភាព ក្រោមមូលបទ « វិវត្ត » |
| **ចំនួនដែលត្រូវជ្រើសរើស** | **៤ កន្លែង** |
| **គម្រោង & រយៈពេល** | គម្រោងត្រូវតែកើតឡើងនៅចន្លោះពី **ខែឧសភា ដល់ ខែធ្នូ ឆ្នាំ២០២៥** |
| **កាលបរិច្ឆេទសំខាន់ៗ** | ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៥ ៖ ប្រកាសទទួលពាក្យស្នើសុំមូលនិធិដំឡើងស្នាដៃថ្មី<br>ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ ៖ បិទទទួលពាក្យ<br>ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ ៖ ប្រកាសអ្នកទទួលជ័យលាភី មូលនិធិដំឡើងស្នាដៃថ្មី |
| **ចំនួនថវិកា** | **៥០០០** ដុល្លារអាមេរិក |

**អំពីមូលនិធិ «ដំឡើងស្នាដៃថ្មី និងមូលបទឆ្នាំ២០២៥»**

គម្រោងមូលនិធិដំឡើងស្នាដៃថ្មីក្នុងឆ្នាំ២០២៥នេះ នាំមកជូននូវមូលបទ **«វិវត្ត»**។ យើងសង្កេតឃើញថាអស់រយៈកាល ៥០ឆ្នាំមកហើយ បន្ទាប់ពីការដួលរំលំនៃទីក្រុងភ្នំពេញនិងការចាប់ផ្តើមនៃរបបខ្មែរក្រហម។ គម្រោងមូលនិធិក្នុងឆ្នាំនេះ មានបំណងរំលេចរឿងរ៉ាវផ្សេងៗអំពីការវិវត្តរបស់កម្ពុជាតាមរយៈសិល្បករបីជំនាន់។ នេះគឺជាឱកាសក្នុងការឧទ្ទិស និងចងចាំចំពោះព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់នេះស្របពេលជាមួយគ្នានេះវាក៏ជាពេលវេលាដ៏សំខាន់ក្នុងការឆ្លុះបញ្ចាំង អំពីដំណើរការវិវត្តរបស់កម្ពុជាផងដែរ។ តើវិស័យសិល្បៈកម្ពុជាមានការផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះពីមួយជំនាន់ទៅមួយ ជំនាន់បន្ទាប់ពីសម័យកាលខ្មៅងងឹតនោះ? តើការបង្ហាញចេញនូវរឿងរ៉ាវផ្សេងៗតាមបែបសិល្បៈ (អំពីបរិស្ថាន នគរូប នីយកម្ម ។ល។ ជាទម្រង់ របាំ ល្ខោន តន្ត្រី ក្តី បានផ្លាស់ប្តូរយ៉ាងដូចម្តេចក្នុងបរិបទសង្គមដែលផ្លាស់ប្តូរឥតឈប់ឈរនេះ?

ក្រោមប្រធានបទ **«វិវត្ត»** ពួកយើងសូមអញ្ជើញសិល្បករ សហគមន៍សិល្បៈ ដែលជាយុវជនជំនាន់ថ្មីដែលមានសក្តានុពល និងទេពកោសល្យសិល្បៈឱ្យមកចូលរួមជាមួយពួកយើងក្នុងដំណើរស្វែងរកចម្លើយនិងអត្ថន័យ ដើម្បីឆ្លើយតបទៅនឹងសំណួរខាងលើតាមរយៈការបង្ហាញនូវស្នាដៃសិល្បទស្សនីយភាពដែលមានភាពច្នៃប្រតិដ្ឋនិងភាពចម្រុះ។

សម្រាប់ឆ្នាំ២០២៥នេះ មូលនិធិដំឡើងស្នាដៃថ្មីនៅតែរក្សារចនាសម្ព័ន ៣ស្រទាប់ដដែលមានដូចជា៖

- មូលនិធិទី១៖ «មូលនិធិសម្រាប់អនុវត្តគម្រោង» ថវិកាចំនួន ៣០០០ដុល្លារអាមេរិក សម្រាប់ឱ្យអ្នកទទួលមូលនិធិយកទៅអនុវត្តដំណើរការនៃការដំឡើងស្នាដៃ
- មូលនិធិទី២៖ «មូលនិធិសម្រាប់អ្នកប្រឹក្សាផ្នែកសិល្បៈ» ថវិកាចំនួន ១០០០ដុល្លារអាមេរិក សម្រាប់ឱ្យអ្នកទទួលមូលនិធិធ្វើការជាមួយអ្នកប្រឹក្សាផ្នែកសិល្បៈ
- មូលនិធិទី៣៖ «មូលនិធិសម្រាប់ការធ្វើបទបង្ហាញ» ថវិកាចំនួន ១០០០ដុល្លារអាមេរិក សម្រាប់ឱ្យអ្នកទទួលមូលនិធិយកទៅប្រើប្រាស់ដើម្បីដាក់បង្ហាញស្នាដៃនៅពេលបញ្ចប់

### ១. វត្ថុបំណងរបស់មូលនិធិ

មូលនិធិដំឡើងស្នាដៃថ្មីបង្កើតឡើងក្នុងវត្ថុបំណងដូចខាងក្រោម៖

- លើកទឹកចិត្តសិល្បករឱ្យបង្កើតភាពច្នៃប្រតិដ្ឋកាន់តែច្រើន តាមរយៈការបង្កើតស្នាដៃថ្មី ឬ ការអភិវឌ្ឍស្នាដៃថ្មីដែលមានស្រាប់
- បង្កើតជាវេទិកាមួយសម្រាប់សិល្បករធ្វើការចែករំលែក និងឆ្លុះបញ្ចាំងអំពីសង្គមកម្ពុជានាពេលបច្ចុប្បន្នតាមរយៈស្នាដៃច្នៃប្រតិដ្ឋរបស់ខ្លួន
- អភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សិល្បករ ដោយផ្តោតទៅលើការដឹកនាំគម្រោង និងការធ្វើការងារជាក្រុម

## ២. អត្ថប្រយោជន៍

សិល្បករនឹងទទួលបានការឧបត្ថម្ភជាមូលនិធិសរុបចំនួន **៥០០០ ដុល្លាអាមេរិក**។ លើសពីការទទួលបានការឧបត្ថមសិល្បករនឹងទទួលបានការបណ្តុះបណ្តាលមូលដ្ឋាននៃការគ្រប់គ្រង និងដឹកនាំគម្រោងដែលផ្តល់ដោយអង្គការសិល្បៈខ្មែរអមតៈ។ សិល្បករនឹងបានស្វែងយល់ពីរបៀបនៃការធ្វើការងារជាក្រុម ការគ្រប់គ្រងពេលវេលា និងការបែកចែកតួនាទីនៅក្នុងដំណើរនៃការដំឡើងស្នាដៃផងដែរ។ មូលនិធិសម្រាប់អ្នកប្រឹក្សាផ្នែកសិល្បៈក៏នឹងជួយបង្ហាញផ្លូវដល់សិល្បករក្នុងការផ្ចិតផ្ចង់គំនិតសិល្បៈរបស់ខ្លួនទៅក្នុងស្នាដៃនេះដែរ។

## ៣. សិល្បករគោលដៅសម្រាប់ផ្តល់មូលនិធិ

- សិល្បករវ័យក្មេង ឬជាសិល្បករមានពិសោធន៍ច្រើនគួរសម ហើយមានការតាំងចិត្តខ្ពស់ចំពោះអាជីពរបស់ខ្លួន
- សិល្បករដែលធ្វើការក្នុងទម្រង់ទស្សនីយភាព (មានដូចជា ល្ខោន របាំ តន្ត្រី) ឬជាសិល្បករដែលធ្វើការលើពហុទម្រង់ តែត្រូវតែយកទម្រង់ទស្សនីយភាពជាគោល ល្ខោននិងសិល្បៈបង្គុំ តន្ត្រីនិងគំនូរ របាំនិងកុន ។ល។
- សិល្បករឯកត្តបុគ្គល ក្រុមសិល្បករ ឬសិល្បៈសហគមន៍ (ចំពោះក្រុមសិល្បករឬសិល្បៈសហគមន៍ សូមដាក់ឈ្មោះអ្នកដឹកនាំក្រុមនៅក្នុងពាក្យស្នើសុំតែប៉ុណ្ណោះ)

**បញ្ជាក់៖** អាទិភាពចំបងនឹងផ្តល់ទៅកាន់បេក្ខភាពស្ត្រីចំនួន **២កន្លែង**

## ៤. លក្ខខណ្ឌជ្រើសរើស

ដើម្បីអាចដាក់ពាក្យស្នើសុំមូលនិធិដំឡើងស្នាដៃថ្មីបាន បេជនក្ខជនត្រូវតែគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ស្នាដៃដែលគ្រោងបង្កើតថ្មី ឬក៏ជាស្នាដៃបង្កើតថ្មីដែលមានស្រាប់ ត្រូវការអភិវឌ្ឍបន្ថែម
- បេក្ខជនអាចដាក់ពាក្យស្នើសុំជាលក្ខណៈបុគ្គល ឬជាក្រុម តែក្រុមនោះត្រូវមានសមាជិកមិនលើសពី ៨នាក់ ឡើយ (ចំពោះការដាក់ពាក្យស្នើសុំលក្ខណៈជាក្រុមសូមដាក់តែឈ្មោះអ្នកតំណាងក្រុមម្នាក់គត់)
- ស្នាដៃត្រូវមានរយៈពេលសម្តែងយ៉ាងតិច ៣០នាទី និងមិនលើសពី ៤៥នាទី
- បេក្ខជនកំពុងស្នាក់នៅក្នុងប្រទេសមកម្ពុជាអំឡុងពេលនៃការអនុវត្តគម្រោង និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន ឬទិដ្ឋាការ K-Visa
- ពាក្យស្នើសុំត្រូវតែជាពាក្យស្នើសុំដែលចេញដោយអង្គការសិល្បៈខ្មែរអតមៈតែប៉ុណ្ណោះ
- បេក្ខជនអាចសរសេរពាក្យស្នើសុំដោយដៃ ឬដោយកុំព្យូទ័រ ជាភាសាខ្មែរ ឬអង់គ្លេស។ ម៉្យាងវិញទៀតបេក្ខជនក៏អាចថតចម្លើយជាវីដេអូ ឬជាសំឡេងក៏បាន។ ប្រសិនបើបេក្ខជនមានការលំបាកក្នុងការបំពេញពាក្យស្នើសុំ បេក្ខជនអាចទាក់ទងតាមរយៈលេខទូរស័ព្ទ ០៧៧ ៧៩៣ ៥៣៧ / ០១០ ៤៨៣ ៩៤៧
- ពាក្យស្នើសុំអាចផ្ញើមកតាមរយៈអ៊ីម៉ែល samath@cambodianlivingarts.org ឬអាចយកមកដាក់ផ្ទាល់នៅការិយាល័យអង្គការសិល្បៈខ្មែរអមតៈ ដែលមានអាស័យដ្ឋាននៅ ផ្ទះលេខ១៣E ផ្លូវលេខ ៨៣០ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
- បេក្ខជនចាំបាច់ត្រូវតែពន្យល់ពីមូលហេតុក្នុងការជ្រើសរើសយកអ្នកប្រឹក្សាផ្នែកសិល្បៈមកជួយនៅក្នុងគម្រោងរបស់ខ្លួនដូចជា៖
  - ប្រវត្តិរូបសង្ខេបរបស់អ្នកប្រឹក្សា
  - ភាពសីគ្នានៃជំនាញរបស់អ្នកប្រឹក្សាទៅនឹងគម្រោងមូលនិធិ
  - ទំនាក់ទំនងរបស់អ្នកនិងអ្នកប្រឹក្សា
  - អ្នកចង់បានការគាំទ្របែបណាពីអ្នកប្រឹក្សាសិល្បៈ
- ពាក្យស្នើសុំរបស់បេក្ខនត្រូវភ្ជាប់មកជាមួយនូវលិខិតគាំទ្រពីស្ថាប័នដែលខ្លួនកំពុងបំពេញការងារ

**ការតាំងចិត្ត៖**

- បេក្ខជនត្រូវមានពេលវេលាគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងមូលនិធិនេះឱ្យសម្រេចបានជោគជ័យ
- បេក្ខជនត្រូវបង្ហាញពីជីវប្រវត្តិនៅក្នុងទម្រង់ទស្សនីយភាព ចំណាប់អារម្មណ៍ ឆន្ទៈ ចក្ខុវិស័យ និងត្រូវបង្ហាញពីគម្រោងបង្កើតស្នាដៃថ្មីរបស់ខ្លួន

- បេក្ខជនត្រូវបង្ហាញពីការតាំងចិត្តទៅលើការបំពេញរបាយណ៍ (ភាសាខ្មែរ ឬ អង់គ្លេស) ដោយគម្រូរបាយការណ៍នឹងផ្តល់ជូនដោយក្រុមការងារសិល្បៈខ្មែរអមតៈ។ របាយណ៍ទាំងនេះត្រូវបញ្ចប់ឱ្យបានយ៉ាងយូរ១ខែ បន្ទាប់ពីគម្រោងរបស់អ្នកដំឡើង និងដាក់បង្ហាញរួចរាល់។

**បេក្ខជនអាទិភាព**

សិល្បៈខ្មែរអមតៈនឹងផ្តល់អាទិភាពដល់បេក្ខភាពដែលមិនធ្លាប់ទទួលបានឱកាសនេះពីមុនមក។ បរិយាបន្ន និងសមភាព គឺជាគុណម្លៃស្នូលរបស់អង្គការសិល្បៈខ្មែរអមតៈដោយហេតុនេះហើយជ័យលាភី ៥០% នឹងផ្តល់ជូនទៅកាន់បេក្ខភាពស្រ្តី។ សិល្បៈខ្មែរអមតៈសូមលើកទឹកចិត្តជាពិសេសចំពោះបេក្ខជនមកពីសហគមន៍ដែលមានសំឡេងតិច ហើយពួកយើងនឹងផ្តល់ការគាំទ្រដល់ជាចាំបាច់ដល់បេក្ខជនដែលមានការលំបាកក្នុងការបំពេញពាក្យស្នើសុំនេះ។

**សំគាល់៖** សម្រាប់ពាក្យស្នើសុំណាដែលមិនគោរពទៅតាមលក្ខខណ្ឌខាងលើ នឹងមិនត្រូវបានពិចារណាក្នុងការជ្រើសរើសឡើយ។

## ៥. គម្រោងនិងរយៈពេល

គម្រោងដែលទទួលបានមូលនិធិនេះ ត្រូវតែអនុវត្តនៅចន្លោះពី **ខែឧសភា ដល់ ខែធ្នូ ឆ្នាំ ២០២៥**

**បញ្ជាក់៖** អ្នកទទួលបានមូលនិធិត្រូវតែបង្ហាញអំពីគម្រោងការណ៍នៃការអនុវត្តគម្រោងដំឡើងស្នាដៃឱ្យបានច្បាស់លាស់នៅក្នុងពាក្យស្នើសុំ (រយៈពេលនៃការអនុវត្តគម្រោងយ៉ាងតិចបំផុតរយៈពេល **៣ខែ**)

## ៦. ក្រុមការងារសម្របសម្រួលមូលនិធិ

មូលនិធិនេះសម្របសម្រួលដោយ លោក ថា សំអាត ដែលអាចទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ **០៧៧ ៧៩៣ ៥៣៧ / ០១០ ៤៨៣ ៩៤៧** និងអ៊ីម៉េល **samath@cambodianlivingarts.org** ។

## ៧. អំពីកាលបរិច្ឆេទសំខាន់ៗ

- ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០២៤ - បើកប្រកាសទទួលពាក្យស្នើសុំមូលនិធិដំឡើងស្នាដៃថ្មី
- ថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២៤ - បិទទទួលពាក្យ
- ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២៤ - ប្រកាសជ័យលាភីអ្នកទទួលបានមូលនិធិ

**របៀបដាក់ពាក្យ**

សូមបំពេញព័ត៌មានរបស់អ្នកនិងឆ្លើយសំណួរនៅក្នុងពាក្យស្នើសុំដែលអាចទាញយកតាមរយៈ **តំណភ្ជាប់នេះ**

**វគ្គសំណួរនិងចម្លើយ**

ពួកយើងនឹងបើកវេទិកាសំណួរចម្លើយតាមអនឡាញ ដែលអ្នកនឹងមានឱកាសជួបជាមួយនឹង «ក្រុមការងារអង្គការសិល្បៈអមតៈ» ដើម្បីពិភាក្សាជុំវិញមូលនិធិ និងដំណើរការនៃការដាក់ពាក្យ។

កាលបរិច្ឆេទ៖ **ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥** ចាប់ពី ម៉ោង៥:៣០ដល់ម៉ោង៧:00ល្ងាច ដោយចូលតាមតំណភ្ជាប់ខាងក្រោម៖

Zoom link: https://us02web.zoom.us/j/8127047219?omn=84707618707

Meeting ID: 812 704 7219